# ឯកឧត្តម ចម ប្រសិទ្ធ ជួបទីប្រឹក្សាពាណិជ្ជកម្ម និងសេដ្ឋកិច្ចនៃស្ថានទូតចិនប្រចាំកម្ពុជា ទើបតែងតាំងថ្មី និងជួបនាយកក្រុមហ៊ុន KOIMA Holding Co.Ltd កូរ៉េ

នៅរសៀលថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតឱ្យលោក **Jin Juan** ទីប្រឹក្សាពាណិជ្ជកម្ម និងសេដ្ឋកិច្ច នៃស្ថានទូតចិនប្រចាំកម្ពុជា ទើបតែងតាំងថ្មី ចូលជួប សំដែងការគួសម និងពិភាក្សាការងារនៅទីស្តីការក្រសួង ។

លោក **Jin Juan** ទីប្រឹក្សាពាណិជ្ជកម្ម និងសេដ្ឋកិច្ច នៃស្ថានទូតចិនប្រចាំកម្ពុជា ទើបតែងតាំងថ្មី បាន ជំរាបជូនថា: រូបលោកធ្លាប់បំពេញការងារ នៅក្នុងក្រសួងពាណិជ្ជកម្ម នៃប្រទេសចិន ទទួលបន្ទុកកិច្ចសហប្រតិ-បត្តិការសេដ្ឋកិច្ច ក្នុងតំបន់អាស៊ាន។ ហើយលោកក៏បានចូលរួមធ្វើកិច្ចការជាច្រើនទាក់ទងនិងកិច្ចព្រមព្រៀង ពាណិជ្ជកម្ម រវាងចិន និងអាស៊ាន ហើយដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានកាលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ កន្លងទៅនេះ សំរាប់សមាជិក ប្រទេសអាស៊ានចាស់ចំនួន ០៦ ប្រទេស ដោយឡែកប្រទេសកម្ពុជា នឹងត្រូវ អនុវត្តនាឆ្នាំ ២០១៥ ខាងមុខនេះ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសំដែងការស្វាគមន៍ និងវាយតំលៃខ្ពស់ចំពោះទំនាក់ទំនងដ៏ល្អ រវាង កម្ពុជា-ចិន លើវិស័យសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងថ្លែងអំណរគុណដល់ប្រទេសចិនដែលបានផ្តល់ភាពអនុគ្រោះ ពាណិជ្ជកម្ម ដល់កម្ពុជានូវមុខទំនិញជាង៤០០មុខ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានសំដែងនូវការអបអរសាទរ ចំពោះការចូលជាធរមាន នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងចិន-អាស៊ាន នៅដើមឆ្នាំ ២០១០ នេះ ។ជាមួយគ្នានេះ ឯកឧត្តម បានស្នើឱ្យប្រទេសចិនបញ្ជូនអ្នកជំនាញមកធ្វើបទឧទ្ទេសនាម ក្នុងសិក្ខាសាលា ដើម្បីផ្សព្វផ្សាយ កិច្ចព្រមព្រៀងនេះ ឱ្យបានទូលំទូលាយដល់ វិស័យឯកជន ព្រមទាំងធ្វើបទបង្ហាញពីលក្ខខ័ណ្ឌតំរូវ ក៏ដូចជាបែបបទ នានា ដូចជា: វិធានប្រភពដើមទំនិញជាដើម ដល់វិស័យឯកជន ដែលមានបំណងនាំចេញទំនិញពីកម្ពុជា ទៅ ប្រទេសចិន ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានថ្លែងអំណរគុណដល់ប្រទេសចិនផងដែរ ដែលបានបង្កលក្ខណៈ ងាយស្រួលដល់កម្ពុជាក្នុងការចូលរួមព្រឹត្តិការណ៍តាំងពិព័រណ៍ធំៗ នៅប្រទេសចិន ហើយឆ្នាំនេះកម្ពុជា ក៏នឹងចូលរួម ពិព័រណ៍ពិភពលោក សៀងហៃ ឆ្នាំ២០១០ ផងដែរ ។

ដោយឡែកនៅរសៀលថ្ងៃដដែលនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតឱ្យលោក **G.H Jang** នាយកក្រុមហ៊ុន **KOIMA Holding Co.Ltd** នៃសាធារណរដ្ឋកូរ៉េ ចូលជួបពិភាក្សាការងារ ទាក់ទងនិង ការស្វែងរក ឱកាសវិនិយោគនៅកម្ពុជា ។

លោកប្រធានក្រុមហ៊ុន KOIMA បានជំរាបជូនថា ៖ ដំណាក់កាលដំបូង ក្រុមហ៊ុនត្រៀមរៀបចំបើក ការិយាល័យ តំណាងរបស់ខ្លួននៅកម្ពុជា និងបន្ទាប់មកទៀត នឹងធ្វើការសិក្សាស្រាវជ្រាវជ្រើសរើសមុខទំនិញរបស់ កម្ពុជា ដែលអាចប្រកួតប្រជែងលើទីផ្សារកូរ៉េបាន។ ក្រៅពីនោះ ក៏មានការវិនិយោគលើវិស័យរោងចក្រ និង សំណង់ផងដែរ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានសំដែងការស្វាគមន៍ ព្រមទាំងជំរាបជូនពីសក្តានុពលសេដ្ឋកិច្ចនៅកម្ពុជា ដែលជាប្រទេសអភិវឌ្ឍន៍តិចតួចមួយ បានទទួលភាពអនុគ្រោះពាណិជ្ជកម្ម ពីប្រទេសអភិវឌ្ឍន៍ជាច្រើន ។ ឯកឧត្តម បានបញ្ជាក់ថាៈ ក្រុមហ៊ុនកូរ៉េ អាចបង្កើតទីតាំងផលិតកែច្នៃនៅកម្ពុជា ហើយអាចនាំទំនិញ រឺផលិតផលទៅទីផ្សារ ដែលកម្ពុជា ទទួលភាពអនុគ្រោះពាណិជ្ជកម្ម ដោយមិនជាប់ពន្ធ និងមិនជាប់កូតានាំចេញ ។